# ធម្មទេសនារបស់លោកអភិបាល អូលីវីយេ
# អភិបូជាជាមួយអដ្ឋិធាតុរបស់សន្ត លូវីស និងសន្តី ហ្សេលី ម៉ាតាំង
# អភិយក្សត្រ ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៩
## គ្រួសារដែលបានយកព្រះកាយព្រះគ្រីស្តជាអាទិភាពនៅក្នុងជីវិតផ្ទាល់ខ្លួន

**អត្ថបទទី១៖ ថេស្សាឡូនិក ទី១ ៤,១-៨**

ម្នាក់ៗត្រូវចេះរួមរស់ជាមួយភរិយាករបស់ខ្លួន ដោយវិសុទ្ធ និងថ្លៃថ្នូរ។ ១ថស ៤,៤

**ដំណឹងល្អ៖ ម៉ាថាយ ២៥,១-១៣**

ចូរអ្នករាល់គ្នាប្រុងស្មារតី ដ្បិតអ្នករាល់គ្នាពុំដឹងថា បុត្រមនុស្ស*នឹងមកដល់ថ្ងៃណា ពេលណាឡើយ។ មថ ២៥,១៣

បងប្អូនជាទីស្រឡាញ់!

តាមពិតធាតុរបស់សន្ត លូវីស និងសន្តី ហ្សេលី បានមកដល់ប្រទេសកម្ពុជានៅថ្ងៃច័ន្ទនិងខ្ញុំដើរតាមមណ្ឌលសកម្មភាពនីមួយៗ រាល់អភិបូជាដែលខ្ញុំថ្វាយខ្ញុំមានប្រធានបទខុសៗគ្នា ដើម្បីទេសនាទាក់ទងនឹងជីវិតប្តីប្រពន្ធទាំងពីរនាក់។ ប្រធានបទដែលខ្ញុំបានរើសនៅថ្ងៃនេះ គឺព្រះកាយព្រះគ្រីស្តមានសារៈសំខាន់បំផុតសម្រាប់ជីវិតរបស់យើងជាប្តីប្រពន្ធនិងជាមេគ្រួសារ។ ហ្សេលី និង លូវីស ទាំងពីរនាក់ពេលគេនៅក្មេងគេចង់ធ្វើជាបងស្រី និងជាបូជាចារ្យ លូវីស បានយកចិត្តទុកដាក់ត្រៀមខ្លួនដើម្បីចូលទេវវិទ្យាល័យ និងហ្សេលី គាត់យកចិត្តនៅក្នុងក្រុមគ្រួសារដូនជីដើម្បីទៅជាបងស្រីមួយរូបនៅក្នុងព្រះសហគមន៍កាតូលិក។ ប៉ុន្តែ ទាំងពីរនាក់មិនបានទៅមុខដោយសារខាង លូវីស គាត់រៀនមិនសូវពូកែគេថាគាត់គ្មានសមត្ថភាពដើម្បីធ្វើជាបូជាចារ្យ ដូច្នេះគេឲ្យគាត់ឈប់ហើយគាត់ទៅធ្វើការជាជាងនាឡិកា។ ហ្សេលី គេឃើញសមត្ថភាពគាត់ដើម្បីធ្វើជាដូនជីមិនបានទេ ដូច្នេះគេឲ្យគាត់ឈប់ហើយគាត់ធ្វើការជាជាងប៉ាក់។ ទាំងពីរនាក់ មានថ្ងៃមួយគេដើរនៅលើស្ពាន (ឈ្មោះថាសន្តឡេអូណា) ពេលគេឃើញមុខគ្នាទៅវិញទៅមកគេធ្លាក់នៅក្នុងរឿងស្នេហា ៣ខែក្រោយមក គេរៀបការនិងបានទៅជាប្តីប្រពន្ធដែលស្រឡាញ់គ្នាមែនទែន។

ដូច្នេះ ខ្ញុំជឿថា ហានណា និងពេរ៉ូ ចាំដែរកន្លែងដែលបានជួបគ្នាលើកដំបូង និងចង់ធ្វើជាប្រពន្ធប្តីនិងគ្នា។ បងប្អូនដែលនៅទីនេះ ដែលបានរៀបការហើយក៏នៅចាំដែរបានជួបជាមួយប្តីបានជួបជាមួយប្រពន្ធនៅពេលណា នៅកន្លែងណា លើកដំបូងដែលបានមើលមុខគ្នានិងថាបងនេះអូននេះអនាគតជាប្តីខ្ញុំជាប្រពន្ធខ្ញុំ។ ក្រោយមកគេចាប់ផ្តើមមានកូន គ្រួសារនេះគេគិតដូចនេះ "**យើងចង់មានកូនច្រើន ដោយសារយើងចង់អប់រំកូនឲ្យកូនយើងស្គាល់ព្រះយេស៊ូ និងអាចមាន**

**ជីវិតអស់កល្បជានិច្ចនៅស្ថានបរមសុខ**" គេមានកូនទាំងអស់ប្រាំបួននាក់។ គេអនុវត្តន៍ព្រះបន្ទូលរបស់ព្រះជាម្ចាស់ "**សូមគ្រប់គ្រងផែនដី និងសូមបង្កើតកូនយ៉ាងច្រើន**" នេះគឺជាគំរូមួយសម្រាប់គ្រួសារថ្មីៗ។ គាត់មានកូន៩នាក់ ប៉ុន្តែនៅក្នុងនោះមាន៤នាក់ដែលទទួលមរណភាពតាំងពីទារកម្លេះ ដោយសារសម័យនោះឥតទាន់មានមន្ទីរពេទ្យ។ គាត់យកចិត្តទុកដាក់អប់រំកូនដែលនៅរស់កូនស្រី៥នាក់ដោយៈ

- ✓ ឲ្យស្រឡាញ់ព្រះជាម្ចាស់
- ✓ ឲ្យស្គាល់ព្រះយេស៊ូយ៉ាងច្បាស់
- ✓ ឲ្យគោរពឪពុកម្តាយ
- ✓ ឲ្យស្រឡាញ់គ្នាជាបងប្អូនបង្កើត។

កូនស្រីទាំងប្រាំនាក់ បានរៀនអស់សមត្ថភាព បានអធិដ្ឋានពេលភ្ញាក់ពីដេកពេលចូលដេកជាមួយឪពុកម្តាយ រាល់អាទិត្យសប្បាយចិត្តចូលអភិបូជា រហូតដល់ទាំងប្រាំនាក់បានសុំធ្វើជាដូនជី។ ដូច្នេះ កូនស្រីទាំងប្រាំទៅជាបងស្រីនៅក្នុងអារាម បួននាក់នៅក្នុងអារាមសម្ងាត់ក្នុងនេះមានសន្តិតេរេសានៃព្រះកុមារយេស៊ូ និងម្នាក់ទៀតក្នុងក្រុមបងស្រីផ្សេង។ ខ្ញុំមានបងប្អូនបួននាក់ ប៉ុន្មានខែមុនយើងបានរៀបចំពិធីខួប៥០ឆ្នាំនៃអាពាហ៍ពិពាហ៍ឪពុកម្តាយខ្ញុំ នៅពេលឪពុកខ្ញុំឡើងសន្ទរកថា ដើម្បីអរព្រះគុណព្រះជាម្ចាស់សម្រាប់កូនៗគាត់។ គាត់ចាប់ផ្តើមរាប់កូនចៅគាត់ឃើញកូនទីបួនបានកូនពីរនាក់ កូនទីបីបានបីនាក់ និងកូនទីពីរបានកូនបីនាក់ ឪពុកខ្ញុំអរព្រះគុណព្រះជាម្ចាស់សម្រាប់កូនចៅ៨នាក់។ ពេលនោះខ្ញុំឈឺចិត្តម្យ៉ាង ឪពុកខ្ញុំនឹកឃើញ៨នាក់ដែលគាត់ឃើញផ្ទាល់ភ្នែក ប៉ុន្តែខ្ញុំអត់មានកូនបង្កើតមែនតែខ្ញុំមានកូនចៅច្រើនណាស់ ដូចលោកតាអាប្រាហាំ។ ឪពុកខ្ញុំ គាត់ភ្លេចខ្ញុំមានរាប់រយនាក់ គាត់មិនមែនមានតែកូនចៅ៨នាក់តែគាត់មានរាប់រយនាក់តាមរយៈខ្ញុំនៅប្រទេសកម្ពុជាជាកូនចៅគាត់ដែរ។

ហ្សីលី គាត់ស្លាប់ពេលគាត់អាយុ៤១ឆ្នាំ ដោយសារគាត់មានជម្ងឺមហារីកសុដន់ នៅសម័យនោះគេអត់ចេះព្យាបាល ពេលនោះសន្តីតេរេសានៃព្រះកុមារយេស៊ូ មានអាយុទើបតែ៤ឆ្នាំ។ លូវីស គាត់យកចិត្តទុកដាក់ដើម្បីចិញ្ចឹមថែរក្សាកូន ស្រឡាញ់កូន ឲ្យកូនរស់នៅតាមរបៀបត្រឹមត្រូវ ឲ្យកូនរៀនសូត្រ ឲ្យកូនមានសីលធម៌ក្នុងខ្លួន ឲ្យកូនស្រឡាញ់ព្រះជាម្ចាស់ ដើម្បីណែនាំឲ្យកូនពោរពេញដោយសេរីភាព។ គាត់មិនដែលមានគំនិតថាចង់ឲ្យកូនគាត់ចូលអារាមទាំងអស់ទេ ជាពិសេសនៅពេលសន្តីតេរេសាចូលអារាមគាត់ឈឺចិត្តដែរ ដោយសារគាត់ស្រឡាញ់កូនពៅគាត់ ប៉ុន្តែគាត់ធ្វើតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់។ សន្តីតេរេសា នៅពេលនឹកឃើញរបៀបដែលឪពុកគាត់បានស្រឡាញ់គាត់មែនទែន នៅពេលហ្នឹងគាត់មានបទពិសោធន៍យ៉ាងពិសេស

អំពីរបៀបដែលព្រះបិតាបានស្រឡាញ់គាត់ដែរ។ ពេលគាត់ឃើញឪពុកគាត់ គាត់ឃើញព្រះបិតានៅស្ថានបរមសុខដែរ ពេលគាត់ឃើញឪពុកម្តាយគាត់ចេះស្រឡាញ់គ្នាទៅវិញទៅមក គាត់នឹកឃើញរបៀបដែលព្រះបិតាស្រឡាញ់យើងនៅលើផែនដីនេះ។ នេះជាគំរូដ៏អស្ចារ្យ ឪពុកម្តាយអត់ដែលពិន័យឬស្តីឲ្យកូនខ្លាំងៗ ប៉ុន្តែណែនាំឲ្យកូនទៅមុខដោយធ្វើជាគំរូសម្រាប់កូន។ គំរូមួយយ៉ាងពិសេស គឺគំរូមួយនៅក្នុងការស្រឡាញ់ព្រះកាយព្រះគ្រីស្ទ។

នៅពេលបានរៀបចំអាពាហ៍ពិពាហ៍ យើងបានរៀនខ្លះៗហើយបានស្តាប់ថា សសរដ៏សំខាន់ ដើម្បីបានទៅជាប្តីប្រពន្ធយ៉ាងច្បាស់លាស់ "**ឲ្យមានចិត្តភក្តីភាពស្មោះត្រង់ចំពោះគ្នាទៅវិញទៅមក**" ទាំងពីរនាក់យើងមានចិត្តស្មោះត្រង់ចំពោះគ្នាទៅវិញទៅមកអស់មួយជីវិត មានន័យថាយើងបាក់បែកគ្នាមិនបានទេ។ យើងជាធ្លុងតែមួយអស់មួយជីវិតនៅមុខព្រះសហគមន៍ នៅមុខព្រះជាម្ចាស់ ទោះបីយើងជួបទុក្ខលំបាក ទោះបីជួនកាលយើងឈ្លោះគ្នាក៏ដោយ ប៉ុន្តែយើងដឹងថា "**យើងជាប្តីប្រពន្ធដែលភ្ជាប់អស់មួយជីវិតនៅក្នុងសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់**"។ មួយទៀត "**បង្កើតកូន**" នេះជាសសរមួយយ៉ាងសំខាន់ឲ្យមានកូនច្រើន ខ្ញុំថែមមួយទៀតសសរមួយដ៏សំខាន់នៅក្នុងជីវិតប្តីប្រពន្ធ "**ចេះសម្រុះសម្រួលគ្នា ចេះលើកលែងទោសឲ្យគ្នាទៅវិញទៅមក**"។ ប៉ុន្មានដងប៉ុន្មានសារ យើងត្រូវតែមានបញ្ហា យើងត្រូវតែឈ្លោះគ្នាខ្លះ ប៉ុន្តែពេលយើងចេះលើកលែងទោសឲ្យគ្នាទៅវិញទៅមក ដោយចេះស្តាប់យោបល់គ្នាទៅវិញទៅមក យើងអាចទៅមុខបន្តិចម្តងៗ។ ម្យ៉ាងទៀត "**ពោរពេញដោយសេចក្តីស្រឡាញ់ ដោយធ្វើជាអង្គតែមួយ ជាធ្លុងតែមួយ**" នឹកឃើញដល់ថ្ងៃដំបូងដែលបានជួបគ្នា ដែលបានមើលមុខគ្នាថាយើងស្រឡាញ់គ្នា។ ចាប់ពីពេលនេះតទៅយើងធ្វើយ៉ាងម៉េចដើម្បីស្រឡាញ់ដូចថ្ងៃដំបូង។

ម្តងៗយើងជូនផ្កាទៅប្រពន្ធ ដើម្បីនឹករលឹកដល់សេចក្តីស្រឡាញ់តាំងពីដើមរៀងមក ដើម្បីថែរក្សាសេចក្តីស្រឡាញ់ពីដើម។ ពីរឆ្នាំមុន ខ្ញុំបានរៀបចំអាពាហ៍ពិពាហ៍នៅខេត្តតាកែវ ខ្ញុំបានទេសនាអំពីសេចក្តីស្រឡាញ់ប្តីប្រពន្ធ ស្នេហាដំបូងត្រូវទៅជាស្នេហាអស់មួយជីវិត ក្រោយមកមានមីងម្នាក់គាត់អាយុប្រហែល៥០ឆ្នាំ ជាពុទ្ធបរិស័ទគាត់និយាយមកខ្ញុំថា "**ពេលខ្ញុំបានស្តាប់លោកឪពុកនិយាយអំពីសេចក្តីស្រឡាញ់រវាងប្តីប្រពន្ធ ចេះស្រឡាញ់គ្នា ចេះបង្ហាញសេចក្តីស្រឡាញ់ទឹកមុខស្រឡាញ់ ចេះបង្ហាញសញ្ញាខ្លះដើម្បីឲ្យដឹងថាយើងនៅស្រលាញ់ដដែល ខ្ញុំការ២០ឆ្នាំហើយនៅក្នុង២០ឆ្នាំកន្លងមកខ្ញុំអត់ដែលនិយាយទៅប្តីខ្ញុំ ថាខ្ញុំស្រឡាញ់គាត់ ហើយថ្ងៃនេះខ្ញុំនឹកឃើញ២០ឆ្នាំនៅជាមួយគ្នា អត់ដែលប្រាប់គាត់ប៉ាវាខ្ញុំស្រឡាញ់ប៉ាវាអត់ដែលសោះ ២០ឆ្នាំចេះតែឈ្លោះគ្នា ចេះតែជេគាត់ ចេះតែវ៉ៃគាត់ ចេះតែអន់ចិត្តជាមួយគាត់ពីព្រឹកដល់យប់ អត់ដែលនិយាយទៅគាត់ថា ខ្ញុំស្រឡាញ់ ដូច្នេះយប់នេះពេលខ្ញុំទៅផ្ទះ ខ្ញុំហៅគាត់ហើយខ្ញុំថាប៉ាខ្ញុំស្រឡាញ់**

**ណាស់**"។ ខ្ញុំឃើញឪពុកម្ដាយខ្ញុំ ថ្ងៃខួបកំណើត ថ្ងៃបុណ្យម្ដាយ ថ្ងៃបុណ្យសន្តម្ដាយខ្ញុំ ឪពុកខ្ញុំមិនដែលភ្លេចជូនកាដូរ ជូនផ្កាទៅម្ដាយខ្ញុំសោះ ទោះបីសព្វថ្ងៃ៥០ឆ្នាំហើយគាត់អត់ដែលភ្លេចទេ នេះសំខាន់ណាស់ដើម្បីថែរក្សាសេចក្ដីស្រឡាញ់អស់មួយជីវិត។

សម្រាប់លូវីស និងហ្សីលី មូលហេតុអ្វីទាំងពីរនាក់នោះអាចស្រឡាញ់គ្នាយ៉ាងខ្លាំងដូចនេះ មូលហេតុអ្វីទាំងពីរនាក់នោះមានចិត្តស្មោះត្រង់យ៉ាងខ្លាំងដូចនេះ? គេមិនមែនប្លែកពីប្ដីប្រពន្ធឯទៀតៗ គេមិនមែនខុសពីគូស្រករដែលរៀបការហើយនៅក្នុងពិភពលោកទាំងមូល ប៉ុន្តែទាំងពីរនាក់រកឃើញប្រភពនៃសេចក្ដីស្រឡាញ់ នៅក្នុងព្រះហឫទ័យស្រឡាញ់របស់ព្រះជាម្ចាស់។ គេមិនទៅរកប្រភពនៃសេចក្ដីស្រឡាញ់នៅកន្លែងផ្សេងទេ គេយល់ថាប្រភពនៃសេចក្ដីស្រឡាញ់ដែលគេបានទទួលនៅថ្ងៃទទួលអគ្គសញ្ញាអាពាហ៍ពិពាហ៍ នៅក្នុងព្រះជាម្ចាស់ ជាពិសេសនៅក្នុងការអធិដ្ឋានប្រចាំថ្ងៃ ដោយសារក្រុមគ្រួសារនេះព្រឹកល្ងាចអធិដ្ឋានជាលក្ខណៈគ្រួសារ និងរៀងៗខ្លួនថែមទៀត។ ជាពិសេស ចូលរួមនៅក្នុងអភិបូជាអគ្គសញ្ញាព្រះកាយព្រះគ្រីស្ដ ដោយយល់ថាជារៀងរាល់ថ្ងៃគេទទួលស្វាគមន៍ព្រះជាម្ចាស់តាមរយៈព្រះកាយព្រះគ្រីស្ដណែនាំឲ្យគេទទួលស្វាគមន៍គ្នាជាប្ដីប្រពន្ធដដែលៗ ប៉ុន្តែក្នុងរបៀបថ្មីៗនៅក្នុងព្រះជន្មរបស់ព្រះយេស៊ូនៅក្នុងព្រះគ្រីស្ដ។ ហ្សីលី ជារៀងរាល់ថ្ងៃគាត់ចូលអភិបូជាម៉ោង៥កន្លះ ជាអភិបូជាសម្រាប់កម្មករ អ្នកក្រីក្រ អ្នកធ្វើការធ្ងន់គ្រួសារនេះមិនមែនក្រប៉ុន្មានទេ ប៉ុន្តែគាត់ចូលអភិបូជានេះជាមួយប្ដីគាត់ដើម្បីបង្ហាញថាគាត់ដាក់ខ្លួន។ រៀងរាល់ថ្ងៃ គាត់ចូលអភិបូជាដោយដឹងថានៅក្នុងអភិបូជាថ្ងៃនេះ ខ្ញុំទទួលព្រះអំណោយទានពិសេសដើម្បីមានកម្លាំងពេញមួយថ្ងៃ ដើម្បីស្រឡាញ់កូនខ្ញុំ ដើម្បីបម្រើកិច្ចការនៅក្នុងផ្ទះ ដើម្បីធ្វើការយ៉ាងត្រឹមត្រូវ ដើម្បីស្រឡាញ់ប្ដីប្រពន្ធថែមទៀត។ លើសពីនេះទៀត គេចូលអភិបូជារហូតដល់ថ្ងៃចុងក្រោយនៃជីវិត ពេលហ្សីលីគាត់ចាប់ផ្ដើមមានជម្ងឺមហារីកសុដន់ គាត់ឈឺមែនទែនដើរមិនរួចប៉ុន្តែខិតខំដើរមួយៗដើម្បីចូលវិហារជារៀងរាល់ថ្ងៃ។

លូវីស គាត់មានជម្ងឺវង្វេងគាត់វង្វេងប៉ុន្តែពេលគាត់មានស្មារតីម្ដងៗ គាត់សុំចូលអភិបូជាភ្លាមៗ ដោយដឹងថាពេលគាត់ទទួលព្រះកាយ គាត់ទទួលព្រះជាម្ចាស់គាត់ទទួលកម្លាំងថ្មី។ ទាំងពីរនាក់ គេធ្លាប់ទទួលព្រះកាយមួយអាទិត្យយ៉ាងតិចបួនដង នៅសម័យនឹងអត់មានទម្លាប់ទទួលព្រះកាយរាល់ថ្ងៃទេ ទទួលព្រះកាយពេលបុណ្យចម្លង បុណ្យព្រះនាងម៉ារីឡើងស្ថានបរមសុខពេលបុណ្យព្រះយេស៊ូប្រសូត មួយឆ្នាំតែបីបួនដង។ ប៉ុន្តែ គ្រួសារនេះទទួលដោយមិនចេះតែទទួលដោយថាអាម៉ែនតែប៉ុណ្ណឹង តែគេរៀបចំចិត្តគំនិតដោយទទួលអគ្គសញ្ញាលើកលែងទោសដោយយកចិត្តទុកដាក់ស្ដាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់។ ជាពិសេស នៅក្នុងជីវិតរបស់ពួកគេ

បានយកចិត្តទុកដាក់លះបង់ចោល និងធ្វើកិច្ចការធម៌មេត្តាករុណាចំពោះអ្នកដទៃ។ ពីរនាក់នោះ គេយកចិត្តទុកដាក់ទទួលអគ្គសញ្ញាលើកលែងទោស យកចិត្តទុកដាក់អធិដ្ឋាន ជាពិសេសខិតខំលះបង់ចោលដើម្បីទៅមុខនៅក្នុងកិច្ចការធម៌មេត្តាករុណា។ ឧទាហរណ៍ លូវីស គាត់សម្រេចចិត្តឈប់ជក់បារី ឈប់ញ៉ាំស្រា គាត់ថាលះបង់ចោលសម្រាប់ព្រះជាម្ចាស់។ ពេលគាត់ធ្វើដំណើរ គាត់មិនជិះរទេះភ្លើងលេខ១ទេគឺគាត់ជិះរទេះភ្លើងលេខ៣ ដើម្បីលះបង់ចោល។ ហ្សឺលី បានយកចិត្តទុកដាក់បម្រើកូនគាត់ បម្រើប្ដីគាត់ ឲ្យគេស្រឡាញ់ព្រះយេស៊ូ ឲ្យគេស្គាល់សន្តសន្តីបុគ្គល ឲ្យគេត្រៀមខ្លួនដើម្បីទទួលព្រះកាយព្រះគ្រីស្ត។ សន្តីតេរេសា នៅពេលគាត់សម្លឹងមើលម្ដាយរបស់គាត់នៅពេលទទួលព្រះកាយម្ដងៗ គាត់យល់ថា "**ពិតមែននេះជាព្រះយេស៊ូយាងចូលនៅក្នុងដួងចិត្តរបស់ឪពុកម្ដាយខ្ញុំ និងណែនាំឪពុកម្ដាយខ្ញុំទៅជាអង្គតែមួយ ជាប្ដីប្រពន្ធនៅក្នុងអង្គព្រះគ្រីស្ត**"។

ថ្ងៃនេះ ទាំងពីរនាក់ដែលទទួលអគ្គសញ្ញាអាពាហ៍ពិពាហ៍ នៅក្នុងអគ្គសញ្ញាអភិបូជាជាការអស្ចារ្យមួយ បន្តិចទៀតខ្ញុំហៅដើម្បីឲ្យព្រះជាម្ចាស់ប្រទានព្រះពរ ជាអគ្គសញ្ញាអាពាហ៍ពិពាហ៍ទៅជាប្ដីប្រពន្ធអស់មួយជីវិត។ ក្រោយមក ទាំងពីរនាក់ទទួលទាំងព្រះកាយទាំងព្រះលោហិតរបស់ព្រះគ្រីស្ត ដើម្បីភ្ជាប់គ្នានៅក្នុងព្រះកាយព្រះលោហិតព្រះគ្រីស្តអស់មួយជីវិត។ អាពាហ៍ពិពាហ៍មានតែម្ដង ប៉ុន្តែទទួលព្រះកាយព្រះគ្រីស្តអាចទទួលរាល់ថ្ងៃក៏បាន រាល់ពេលចូលអភិបូជាសូមនឹកឃើញនៅពេលនោះបីដូចជាខ្ញុំរៀបការម្ដងទៀត ដោយដឹងថាខ្ញុំមានព្រះជាម្ចាស់ដែលនៅគង់ជាមួយខ្ញុំ ដែលស្រឡាញ់ខ្ញុំ។

យើងអរព្រះគុណព្រះជាម្ចាស់ យើងអធិដ្ឋានសម្រាប់ហានណា និងពេរ៉ូ តាមរយៈសន្ត លូវីស និងសន្តី ហ្សឺលី ដើម្បីឲ្យទាំងពីរនាក់ភ្ជាប់នៅក្នុងអគ្គសញ្ញាអាពាហ៍ពិពាហ៍អស់មួយជីវិត។ យើងអធិដ្ឋានសម្រាប់បងប្អូនទាំងអស់ ដើម្បីគ្រួសាររបស់យើងជួនកាលជួបទុក្ខលំបាកឲ្យគ្រួសារយើងទៅមុខតទៅទៀត ដោយទទួលកម្លាំងពីសន្តលូវីស និងសន្តីហ្សឺលី។ អាម៉ែន៕